## របបកម្ពុជាប្រជាធិបតេយ្យ

ប្រទេសកម្ពុជាបានឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ ឬហៅថា របបខ្មែរក្រហម អស់រយៈពេលជិតបួនឆ្នាំ គិតចាប់ពីថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥ ដល់ ៦ មករា ១៩៧៩។ ប្រជាជនកម្ពុជាបានបាត់បង់ជីវិត ប្រមាណជាងមួយលាននាក់ ដោយការកាប់សម្លាប់ ការបង្ខំឲ្យធ្វើការជាទំងន់ ការបង្អត់អាហារ និងការស្លាប់ដោយជំងឺផ្សេងៗក្នុងនោះក៏មានការសម្លាប់ ក្នុងរឿងទំនាក់ទំនងផ្លូវភេទ នឹងមានអំពើហិង្សាផ្លូវភេទជាច្រើនករណីផ្សេងទៀត។

## អំពើហិង្សាផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

តាមការស្រាវជ្រាវរបស់អ្នកជំនាញបានបង្ហាញឱ្យឃើញថា អំពើហិង្សាផ្លូវភេទបានកើតឡើងក្រោមរបបខ្មែរក្រហមរួមមានៈ

- ការរំលោភផ្លូវភេទ (ឧៈ ការរំលោភបូក ដោយមនុស្សច្រើននាក់ ការរំលោភមុនសំម្លាប់ ការរំលោភក្នុងពន្ធធនាគារ...)
- ការធ្វើទារុណកម្មផ្លូវភេទ (ឧៈ ការកាត់អវយវៈភេទ ការប្រើគ្រឿងឆក់ ការគៀបមួលប្រដាប់ភេទដោយ ឧបករណ៏ផ្សេងៗ ឬការដាក់អោយសត្វទិចឬខាំ...)
- ការយាយីខាងផ្លូវភេទ (ឧៈ ការប្រើពាក្យសម្តីមើលងាយទាក់ទងផ្លូវភេទ ការបង្ខំឲ្យអាក្រាតខ្លួន...)
- ការកេងប្រវ័ញ្ចផ្លូវភេទ (ឧៈ ការរួមភេទដើម្បីបានអាហារ ថ្នាំពេទ្យ ឬបានធ្វើការងារស្រាលៗ...)

- ការបង្ខំអោយរៀបការ



*ពិធីរៀបការរបស់ខ្មែរក្រហម (រូបថតឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នេះជាឧទាហរណ៏មួយដែលភាគច្រើនការរៀបការរបស់ពួកគេ ខ្មែរក្រហមបានតំរូវអោយបុរសអង្គុយមួយជួរ និងស្ត្រីអង្គុយមួយជួរ បន្ទាប់មកត្រូវឡើងធ្វើការប្តេជ្ញាចិត្តជាមួយនឹងគូដែលបានកំណត់។ ការរៀបការប្រព្រឹត្តទៅដោយ មិនមានវត្តមានក្រុមគ្រួសារមិត្តភ័ក្តិ និងមិនមានការរៀបចំតាមប្រពៃណីអ្វីទេ។ ភាគច្រើននៃជនរងគ្រោះមិនបានដឹងពី ការរៀបការនេះឡើយពួកគេគ្រាន់តែត្រូវបានហៅមកប្រជុំតែប៉ុណ្ណោះ។ បើទោះជាដឹងមុនពីការរៀបការនេះក៏ពួកគេគ្មានសិទ្ធិ និងមិនហ៊ានប្រកែកដែរ។

## អំពើហិង្សាផ្លូវភេទ និងសាលាក្តីខ្មែរក្រហម

រយៈពេលជិត៣០ឆ្នាំក្រោយពីរបបខ្មែរក្រហមដួលរលំ និងការរង់ចាំ របស់ជនរងគ្រោះមក **អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ឬ **សាលាក្តីខ្មែរក្រហម** ត្រូវបានកើតជារូបរាងឡើងពិតប្រាកដ និងតំណើរការចាប់ពីឆ្នាំ ២០០៧ មក។ មានប្រជាជនរងគ្រោះក្នុងរបបខ្មែរក្រហម បានដាក់ពាក្យបណ្តឹងជាអ្នកប្តឹងធម្មតា ឬជាសាក្សី និងជាដើមបណ្តឹងរដ្ឋប្បវេណីសរុបប្រមាណ ៨.០០០ បានដាក់ទៅកាន់សាលាក្តីនេះ។ ក្នុងនោះមាន ជនរងគ្រោះផ្នែកហិង្សាផ្លូវភេទជាច្រើនពិសេសក្នុងការ បង្ខំឲ្យរៀបការ រាប់រយករណីផងដែរ។ អ្នកដាក់ពាក្យក្នុងករណីបង្ខំឲ្យរៀការនេះ ត្រូវបានទទួលស្គាល់ជា ដើមបណ្តឹងរដ្ឋប្បវេណីដោយ តុលាការមានចំនួន780 នាក់។ កន្លងទៅសាលាក្តីនេះ បានទទួលយកករណី ការបង្ខំឲ្យរៀបការទៅស៊ើបអង្កេតដែលមានវិសាលភាពនៅទូទាំងប្រទេសកម្ពុជា ក្នុងសំណុំរឿងលេខៈ ០០២ ត្រូវបានចោទប្រកាន់ ទៅលើជនត្រូវចោទ ដែលជាមេដឹកនាំជាន់ខ្ពស់ក្នុង របបខ្មែរក្រហមរួមមានៈ **ខៀវ សំផន**, **នួន ជា**, **អៀង សារី** និង **អៀង ធីរិទ្ធ**។ លើលពីនេះនៅក្នុងសវនាការ និងការប្រកាសសាលក្រមលើសំណុំរឿងលេខៈ ០០១ ដែលចោទប្រកាន់លើជនជាប់ចោទឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ក៏មានការចោទប្រកាន់អំពើការរំលោភផ្លូវភេទ មួយករណីនៅក្នុងពន្ធនាគារ ស-២១ ផងដែរ។

## គំរោងអំពើហិង្សាផ្លូវភេទ

ស្របពេលដែល សាលាក្តីខ្មែរក្រហម កំពុងតំណើរកានីតិវិធីរបស់ខ្លួន គំរោងអំពើហិង្សាផ្លូវភេទ នៃ **ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា** បាននិងកំពុងធ្វើការផ្សព្វផ្សាយ ដើម្បីផ្តល់ការយល់ដឹង និងការជួយជនរងគ្រោះអំពើហិង្សាផ្លូវភេទ ក្រោមរបបខ្មែរក្រហម និងជនរងគ្រោះទូទៅពីរបបនេះ។

សកម្មភាពសំខាន់របស់គំរោង រួមមានៈ

### ១. ការផ្សព្វផ្សាយ និង តស៊ូមតិ

- វេទិការស្ត្រី "**ការស្តាប់សម្លេងស្ត្រី ក្នុងសម័យខ្មែរក្រហម**"
- សិក្ខាសាលាស្តីពី "**ការចូលរួមសាធនាការ** "
- សិក្ខាសាលាពីបញ្ហា យេនឌ័រ ជាមួយអង្គការដៃគូ ស្ថាប័នជាដៃគូនានា
- ការស្រាវជ្រាវ និងការចងក្រងជាឯកសារអំពីអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហមដូចជាៈ ( អាថ៌កំបាំងនៃហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម; ដំណើរឆ្ពោះទៅរកការសះជា; ខ្ញុំភ័យស្ទើរលស់ព្រលឹងអស់ពីខ្លួន) ការផលិតវីដីអូខ្លីៗ និងការផ្សព្វផ្សាយតាមរយៈគេហទំព័រ
- កម្មវិធីវិទ្យុ "**ស្ត្រីក្នុងរបបខ្មែរក្រហម** "



វេទិការ "**ការស្តាប់សម្លេងស្ត្រីក្នុងតំបន់ស៊ីប៉ាស៊ីហ្វិក ២០១២**"



កម្មវិធីវិទ្យុ "**ស្ត្រីក្នុងរបបខ្មែរក្រហម**"

## ២. ការគាំពារជនរងគ្រោះ និង ការគាំទ្រខាងផ្លូវចិត្ត



*សិក្ខាសាលាស្តីពី* " **ការចូលរួមសវនាការ** "

- ជួបជាមួយជនរងគ្រោះ សាក្សី ពន្យល់ពីនីតិវិធីតុលាការនិង ដំណើការវិវត្តន៍ថ្មីៗរបស់ សាលាក្តីខ្មែរក្រហម
- ពន្យល់ និងជួយបំពេញពាក្យបណ្តឹង
- ផ្តល់ និងការប្រឹក្សាជាមួយមេធាវី
- ទស្សនាសារមន្ទីរធ្វើទារុណកម្ម និងសាលាក្តី
- ជួបជាមួយអ្នកពិគ្រោះ និងការគាំទ្រផ្លូវចិត្ត
- ជួបជុំរវាងជនរងគ្រោះ និងចងក្រងជាបណ្តាញ
- ជួប " ក្រុមជួយខ្លួនឯង "



**ជនរងគ្រោះដែលបានធ្វើការដាក់ពាក្យបណ្តឹង**

### តើយេនឌ័រ មានអត្ថន័យយ៉ាងដូចម្តេច?

យេនឌ័រ គឺសំដៅយកតួនាទី ឥរិយាបថ គុណតំលៃនានាដែលវប្បធម៌ និងសង្គមបានកំណត់ ហើយការកំណត់បែបយ៉ាងនោះគឺអាស្រ័យដោយកត្តាជាច្រើនយ៉ាង ដូចជាផ្នត់គំនិតនៃសង្គម ទំនៀមទំលាប់ និងការអភិវឌ្ឍន៍របស់សង្គមនីមួយៗ។

### ដូចម្តេចដែលហៅថាភេទ?

ភេទ គឺសំដៅទៅលើភាព ខុសគ្នានៃរូបរាងកាយរវាងបុរស និងស្ត្រីទៅតាមសក្ខណៈជីវសាស្ត្រ។ ការខុសគ្នានេះ មិនអាចកែប្រែបានឡើយ ព្រោះជាការតាក់តែងរបស់ ធម្មជាតិ។

### អ្វីជាអំពើហិង្សា?

អំពើហិង្សា គឺជាការរំលោភបំពានដោយចេតនា ឬការបង្ខិតបង្ខំផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ (ដោយរួមបញ្ចូលទាំងការប្រមាថមាក់ងាយនិងការគំរាមគំហែង) និងការរំលោភបំពានខាងផ្នែកជីវភាពសេដ្ឋកិច្ចផងដែរ។

### អ្វីជាអំពើហិង្សាយេនឌ័រ?

សំដៅលើរាល់ទំរង់ទាំងឡាយ នៃអំពើហិង្សាដែលកើតចំពោះស្ត្រី បុរស កុមារា កុមារី ឬភេទណាមួយផ្សេងទៀត ដែលមានភាពទន់ខ្សោយខុសគ្នារវាងជនរងគ្រោះ និងអ្នកប្រព្រឹត្តដែលរួមទាំងហិង្សាផ្លូវភេទ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

CAMBODIAN DEFENDERS PROJECT

ពង្រឹងសិទ្ធិមនុស្សតាមការកែលំអប្រព័ន្ធច្បាប់ ពង្រឹងធម្មាធិបតេយ្យ និង លទ្ធិប្រជាធិបតេយ្យសេរី

## <u>អាស័យដ្ឋានទំនាក់ទំនង</u>

ផ្ទះលេខ ១LE⁰ ផ្លូវ ៤៥០ សង្កាត់ ទួលទំពូង ២

ខណ្ឌចំការមន ភ្នំពេញ

ទូរសព្ទ័: (០២៣) ២១៤ ០១៩
(០២៣) ២១៤ ០២៩

www.cdpcambodia.org
www.gbvkr.org

<u>ព័ត៏មានបន្ថែមសូមទំនាក់ទំនង</u>

អ៊ីម៉ែល: gbvmail@yahoogroups.com

**ឧបត្ថម្ភដោយ**

ifa Institut für Auslands-beziehungen e. V.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

CAMBODIAN DEFENDERS PROJECT

ពង្រឹងសិទ្ធិមនុស្សតាមការកែលំអប្រព័ន្ធច្បាប់ ពង្រឹងធម្មាធិបតេយ្យ និង លទ្ធិប្រជាធិបតេយ្យសេរី

# អំពើហិង្សាផ្លូវភេទ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

**(Gender-Based Violence under the Khmer Rouge Regime )**




<u>ព័ត៏មានបន្ថែមសូមទំនាក់ទំនង</u>

*លោក ដួង សាវ៉ន: ០១២ ៨០០ ៨១៦*

*អ៊ីម៉ែល :* **gbvmail@yahoogroups.com**